# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 15-Dec-2017, 13:29
CMS/CFO: Sann Rada

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៧

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ (ជាមួយនឹងឧបសម្ព័ន្ធ)

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ: សាធារណៈ

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សេចក្តីសន្និដ្ឋានបន្ថែមរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីបញ្ហាមូលនិធិពាក់ព័ន្ធនឹងគម្រោងសំណងនៅក្នុងសំណុំរឿង ០០២/០២ និងសំណើសុំគោលការណ៍ណែនាំ ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

គឹម ម៉េងឃី

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

ចៅក្រម Claudia FENZ

ឡោ ជុនធី
ម៉ុច សុវណ្ណារី
ស៊ិន សុវ៉ន
សំ សុគង់
វ៉ែន ពៅ
ទី ស្រ៊ីណា
Laure DESFORGES
Ferdinand DJAMMEN NZEPA
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង
Nicholas KOUMJIAN

**ជនជាប់ចោទ៖**

ខៀវ សំផន
នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

Olivier BAHOUGNE

# I. សេចក្តីផ្តើម

១. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") បានដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២/០២ ("សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល") កាលពីថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៧ ដែលក្នុងនោះសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញទិដ្ឋភាពរួមអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២/០២ ហើយបានបង្ហាញនូវព្យសនកម្មដែលបានទទួលរងដោយដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងប្រធានបទជំនុំជម្រះនីមួយៗនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២[1]។ នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៧ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់បណ្តឹងទាមទារសំណងចុងក្រោយ ("បណ្តឹងទាមទារសំណងចុងក្រោយ") ដែលក្នុងនោះសហមេធាវីនាំមុខបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង អនុម័តទៅលើគម្រោងចំនួន ១៧ ជាការផ្តល់សំណងរបស់តុលាការដើម្បីជា ប្រយោជន៍នៃដើមបណ្តឹងរដ្ឋប្បវេណីព្យសនកម្មដែលពួកគាត់បានទទួលរងដោយសារឧក្រិដ្ឋកម្មដែលត្រូវបានជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២[2]។

២. នៅក្នុងបណ្តឹងទាមទារសំណងចុងក្រោយ សហមេធាវីនាំមុខបានស្នើសុំលទ្ធភាពដាក់សេចក្តីសន្និដ្ឋានបន្ថែមនៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ដោយសារមានការកែប្រែលើកាលបរិច្ឆេទនៃការរៀបចំអង្គាសថវិកាពាក់ព័ន្ធនឹងគម្រោងចំនួន ៦ ដែលពុំត្រូវបានធានាការផ្តល់មូលនិធិពេញលេញ។ នៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១៧ អង្គជំនុំជម្រះសាលាដំបូងបានយល់ព្រមតាមសំណើរបស់សហមេធាវីនាំមុខសុំដាក់សេចក្តីសន្និដ្ឋានបន្ថែមស្តីពីបញ្ហាការផ្តល់មូលនិធិយ៉ាងយូរបំផុតត្រឹមថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៧[3]។

---

[1] សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ D457/6/2 ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៧។

[2] បណ្តឹងទាមទារចុងក្រោយរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណងនៅក្នុងសំណុំរឿង ០០២/០២ ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ ឯកសារ D457/6/2/1 ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧ ("បណ្តឹងទាមទារសំណងចុងក្រោយ")។ សហមេធាវីនាំមុខអន្តរជាតិសន្និដ្ឋានថា គម្រោងបន្ថែមមួយត្រូវបានទទួលយកដោយអង្គជំនុំជម្រះសាលាដំបូង។

[3] អនុស្សារណៈអង្គជំនុំជម្រះសាលាដំបូង សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខសុំពន្យារពេលដាក់សេចក្តីសន្និដ្ឋានបន្ថែមដែលមានការបង្ហាញភ័ស្តុតាងអំពីការធានានូវមូលនិធិសម្រាប់គម្រោងសំណងចំនួនប្រាំមួយនៅត្រឹមថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០១៧ ឯកសារ D457/6/2/2 ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៧។

៣. សហមេធាវីនាំមុខសូមដាក់ភស្តុតាងបង្ហាញអំពីការធានានូវមូលនិធិពាក់ព័ន្ធនឹងគម្រោងទី ១៣ និង ទី ១៥។ សហមេធាវីនាំមុខសូមដកចេញនូវគម្រោងទី ១៤ គម្រោងទី ១៦ គម្រោង ទី១៧ និង គម្រោងទី ១៨ ដែលបានស្នើសុំឲ្យពិចារណាដូចបានស្នើឡើងនៅក្នុងបណ្តឹងទាមទារសំណងចុងក្រោយ ដោយសារការផ្តល់មូលនិធិពុំទាន់បានធានាពេញលេញ[4]។

៤. ទោះបីជាសហមេធាវីនាំមុខទទួលស្គាល់ថា សេចក្តីសន្និដ្ឋានរបស់ពួកគេត្រូវបានកម្រិតត្រឹមបញ្ហាមូលនិធិពាក់ព័ន្ធនឹងគម្រោងដែលពុំមានការធានានូវមូលនិធិពេញលេញក៏ដោយ ក៏សហមេធាវីនាំមុខសូមគោរពស្នើសុំគោលការណ៍ណែនាំពីអង្គជំនុំជម្រះ ពាក់ព័ន្ធនឹងការវិវឌ្ឍដែលពុំបានគ្រោងទុកស្តីពីគម្រោងទាំងប្រាំមួយដែលបានទទួលមូលនិធិពេញលេញ ដែលបានស្នើឡើងនៅក្នុងបណ្តឹងទាមទារសំណងចុងក្រោយ។ ដោយសារម្ចាស់ជំនួយនៅបន្តចាប់អារម្មណ៍នៅឡើយ គម្រោងទាំងនេះបានទទួល ឬ ទំនងនឹងបានទទួលមូលនិធិបន្ថែមដើម្បីពង្រីកសកម្មភាពគម្រោង។ សហមេធាវីនាំមុខយល់ឃើញថា ការពង្រីកសកម្មភាពបែបនេះគួរយកមកពិចារណាថាជាការពង្រីកគម្រោងសំណងដែលស្នើឡើង អនុលោមតាមវិធាន ២៣ *ស្ទួនបួន* (៣)(ខ) ដោយសារវាផ្តល់ផលប្រយោជន៍បន្ថែមទៅដល់បណ្តុំដើមបណ្តឹងរដ្ឋប្បវេណីតាមរយៈការបង្កើនចំនួនសិទ្ធិវន្ត និង/ឬ ការបង្កើនការផ្សព្វផ្សាយគម្រោងដែលមានស្រាប់។ ករណីនេះនឹងមានអានុភាពជាក់ស្តែងក្នុងការធានានូវភាពស៊ីសង្វាក់គ្នាក្នុងចំណោមសកម្មភាពគម្រោងដែលមានលក្ខណៈស្រដៀងគ្នា ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសកម្មភាពទាំងនេះ ដោយមានការជូនដំណឹងពីដៃគូគម្រោងសំណងអំពីការវិវឌ្ឍបន្ថែមអំពីគម្រោងរបស់ពួកគេ និងការធានានូវការកំណត់យ៉ាងស៊ីសង្វាក់គ្នានៃសកម្មភាពគម្រោងថាជាផ្នែកមួយនៃគម្រោងសំណងដែលបានស្នើ ឡើង។

## II. សេចក្តីសន្និដ្ឋាន

### ក. គម្រោងទី ១៣៖ គម្រោងលើកកម្ពស់សុខភាព និងសុខុមាលភាពផ្លូវចិត្ត និងកាត់បន្ថយហានិភ័យនៃភាពក្រីក្រ និងការកាត់ផ្តាច់ពីសង្គមនៃដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន និងបុគ្គលចាស់ជរាដែលងាយរងគ្រោះនៅក្នុងប្រទេស

៥. ដូចបានពិពណ៌នានៅក្នុងបណ្តឹងទាមទារសំណងចុងក្រោយ អង្គការ មនុស្សចាស់ កម្ពុជា ដោយមានការគាំទ្រពីសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះបានបង្កើត "គម្រោងលើកកម្ពស់សុខភាព និងសុខុមាលភាពផ្លូវចិត្ត និងកាត់បន្ថយហានិភ័យនៃភាពក្រីក្រ និងការកាត់ផ្តាច់ពីសង្គមនៃដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន និងបុគ្គលចាស់ជរាដែលងាយរងគ្រោះនៅក្នុងប្រទេស" ដើម្បី

[4] បណ្តឹងទាមទារសំណងចុងក្រោយ ឯកសារ D457/6/2/1 កថាខណ្ឌ ១៣ កថាខណ្ឌ ៥៩ កថាខណ្ឌ ៧៣ និងសំណើសុំ។

ជាគម្រោងសំណាងមួយជាប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណី[5]។

៦. នៅពេលឆ្លើយតបទៅនឹងការព្រួយបារម្ភពាក់ព័ន្ធនឹងព័ត៌មានលម្អិតស្ដីពីគម្រោង និងភស្ដុតាងបង្ហាញអំពីការយល់ព្រម និងកិច្ចសហប្រតិបត្តិការរបស់ភាគីទីបីចាំបាច់ក្នុងការអនុវត្តគម្រោង[6] ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងសកម្មភាពគម្រោងអាចរកបាននៅក្នុងកិច្ចព្រមព្រៀងនៃការផ្ដល់ជំនួយគាំទ្ររបស់អង្គការ UNOPS ដូចបានដាក់ជូននៅក្នុងឧបសម្ព័ន្ធ ក រួមជាមួយនឹងលិខិតគាំទ្រពីដៃគូអនុវត្តគម្រោង[7]។ សហមេធាវីនាំមុខកត់សម្គាល់ជាពិសេសថា ព័ត៌មានចុងក្រោយបានបញ្ជាក់បំភ្លឺលើក្របខណ្ឌពេលវេលាសម្រាប់អនុវត្ត និងបានកាត់បន្ថយថវិកាគម្រោង[8]។

៧. នៅក្នុងអំឡុងពេលក្រោយដាក់បណ្ដឹងទាមទារសំណងចុងក្រោយ មូលនិធិសម្រាប់គម្រោងត្រូវបានធានាពេញលេញពីសហភាពអឺរ៉ុប តាមរយៈអង្គការ UNOPS និងភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ[9]។

---

[5] បណ្ដឹងទាមទារសំណងចុងក្រោយ ឯកសារ D457/6/2/1 កថាខណ្ឌ ៦០-៦២ និងឧបសម្ព័ន្ធ ១៣៖ គម្រោងលើកកម្ពស់សុខភាព និងសុខុមាលភាពផ្លូវចិត្ត និងកាត់បន្ថយហានិភ័យនៃភាពក្រីក្រ និងការកាត់ផ្ដាច់ពីសង្គមនៃដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន និងបុគ្គលចាស់ជរាដែលងាយរងគ្រោះនៅក្នុងប្រទេស ឯកសារ D457/6/2/1.1.13។

[6] អនុស្សារណៈអង្គជំនុំជម្រះសាលាដំបូង សេចក្ដីសម្រេចលើសំណើរបស់សហមេធាវីនាំមុខសុំពន្យារពេលដាក់សេចក្ដីសន្និដ្ឋានបន្ថែមដែលមានការបង្ហាញភស្ដុតាងអំពីការធានានូវមូលនិធិសម្រាប់គម្រោងសំណងចំនួនប្រាំមួយនៅត្រឹមថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០១៧ ឯកសារ D457/6/2/2 ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៧ កថាខណ្ឌ ៤។

[7] *សូមមើល* ឧបសម្ព័ន្ធ ក.២៖ ទិដ្ឋភាពរួមនៃគម្រោងសំណងដែលត្រូវបានកែសម្រួល។ ឧបសម្ព័ន្ធ ក.៣៖ ការពិពណ៌នាដៃគូគម្រោង។ ឧបសម្ព័ន្ធ ក.៤៖ លិខិតគាំទ្រពីមន្ទីរសុខាភិបាលខេត្តបាត់ដំបង (មន្ទីរសុខាភិបាលសាធារណៈ)។ ឧបសម្ព័ន្ធ ក.៥៖ លិខិតគាំទ្រពីមន្ទីរសុខាភិបាលអង្គការចិត្តសង្គម អន្តរវប្បធម៌ (អង្គការ TPO នៅកម្ពុជា)។ ឧបសម្ព័ន្ធ ក.៦៖ លិខិតគាំទ្រ និងកិច្ចសហប្រតិបត្តិការដែលចេញដោយសមាគមសហភាពដើម្បីគាំទ្រមនុស្សចាស់ (សមាគមមនុស្សចាស់/OPAs) នៅក្នុងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ស្រុកបាណន់ ខេត្តបាត់ដំបង ស្រុកមោងឫស្សី ខេត្តបាត់ដំបង ស្រុកឯកភ្នំ ខេត្តបាត់ដំបង និងស្រុកពួក ខេត្តសៀមរាប និងលិខិតគាំទ្រចេញដោយសមាគមមនុស្សចាស់ Morth Sreah។ ឧបសម្ព័ន្ធ ក.៨៖ ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ, កិច្ចព្រមព្រៀងនៃការផ្ដល់ជំនួយគាំទ្ររបស់អង្គការ UNOPS (រួមបញ្ចូលព័ត៌មានលម្អិតអំពីគម្រោង និងថវិកាគម្រោង)។

[8] *សូមមើល* ឧបសម្ព័ន្ធ ក.២៖ ទិដ្ឋភាពរួមនៃគម្រោងសំណងដែលត្រូវបានកែសម្រួល។ ឧបសម្ព័ន្ធ ក.៧៖ ថវិកាគម្រោងដែលត្រូវបានកែសម្រួល។

[9] *សូមមើល* ឧបសម្ព័ន្ធ ក.៨៖ ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ កិច្ចព្រមព្រៀងនៃការ ផ្ដល់ជំនួយគាំទ្ររបស់អង្គការ UNOPS (រួមបញ្ចូលព័ត៌មានលម្អិតអំពីគម្រោង និងថវិកាគម្រោង)។ *សូមមើល* ឧបសម្ព័ន្ធ ក.៩៖ ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ, លិខិតគាំទ្រពីទីភ្នាក់ងារស្វីសដើម្បីអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការ។

**ខ. គម្រោង ១៥៖ ជនជាតិដើមភាគតិចកម្ពុជា និង ប៉ុល ពត**

៨. ដូចបានរៀបរាប់នៅក្នុងបណ្តឹងទាមទារសំណងចុងក្រោយ សមាគមវប្បធម៌កម្ពុជា-អាល្លឺម៉ង់ ក្រោមកិច្ចសហប្រតិបត្តិការជាមួយនឹងសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ បាន រៀបចំ និងស្នើសុំអនុវត្តគម្រោង "ជនជាតិដើមភាគតិចកម្ពុជា និង ប៉ុល ពត" ជាគម្រោងសំណង តាមផ្លូវតុលាការនៅក្នុងសំណុំរឿង ០០២/០២[10]។

៩. សហមេធាវីនាំមុខបានទទួលព័ត៌មានបន្ថែមពីដៃគូគម្រោងពាក់ព័ន្ធនឹងការពង្រីកសកម្មភាពដំបូង របស់ខ្លួន ហេតុដូច្នេះ ត្រូវមានការបង្កើនថវិកាដើមនៅក្នុងគម្រោង[11]។

១០. ការផ្តល់មូលនិធិពេញលេញសម្រាប់គម្រោងត្រូវបានធានាពីសហភាពអឺរ៉ុប តាម រយៈអង្គការ UNOPS និងមូលនិធិ Heinrich Böll[12]។ សហមេធាវីនាំមុខកត់សម្គាល់ឃើញថា មូលនិធិបន្ថែម កំពុងស្នើសុំសម្រាប់ការបកប្រែបន្ថែម និងការផ្សព្វផ្សាយខ្សែភាពយន្ត។ ទោះបីជាយ៉ាងនេះក្តី មូល និធិបែបនេះពុំមែនជាសមាសភាពចាំបាច់នៃគម្រោងនោះទេ ហើយគម្រោងនេះអាចអនុវត្តពេញ លេញបាន បើទោះជាគ្មានការផ្តល់នូវមូលនិធិបែបនេះក៏ដោយក្តី។

**គ. សំណើសុំគោលការណ៍ណែនាំពាក់ព័ន្ធនឹងការពង្រីកសកម្មភាពសម្រាប់គម្រោងដែលបានទទួលមូលនិធិ ពេញលេញ**

១១. សហមេធាវីនាំមុខស្នើសុំគោលការណ៍ណែនាំពីអង្គជំនុំជម្រះសាលាដំបូងអំពីរបៀបបន្តកិច្ចការពាក់ ព័ន្ធនឹងការអភិវឌ្ឍគម្រោងក្រោយពេលដាក់បណ្តឹងទាមទារសំណងចុងក្រោយ។ ម្ចាស់ជំនួយ បង្ហាញចំណាប់អារម្មណ៍ចង់បន្ត ឬ បានសន្យាផ្តល់មូលនិធិបន្ថែមសម្រាប់គម្រោងសំណងដែល បានទទួលមូលនិធិពេញលេញរួចហើយ មិនថាវាជាការពង្រីកសកម្មភាពដែលមានស្រាប់សម្រាប់រ យៈពេលយូរជាងមុន និង/ឬ ពង្រីកសកម្មភាពលើទីតាំងបន្ថែមនោះ ឡើយ។ ម្ចាស់ជំនួយបង្ហាញ ចំណាប់អារម្មណ៍ចង់បន្ត ឬ បានសន្យាផ្តល់មូលនិធិសម្រាប់សកម្មភាពបន្ថែមដែលទាក់ទងយ៉ាង ជិតស្និទ្ធជាមួយនឹងសកម្មភាពដូចបានរៀបរាប់នៅក្នុងគម្រោងដើមដែលបានដាក់ជូននៅក្នុងបណ្តឹង

---

[10] បណ្តឹងទាមទារចុងក្រោយ ឯកសារ E457/6/2/1 កថាខណ្ឌ ៦០-៦២ និងឧបសម្ព័ន្ធ ១៥៖ ជនជាតិដើមភាគតិចកម្ពុជា និង របបប៉ុលពត ឯកសារ E457/6/2/1.1.15។

[11] *សូមមើល* ឧបសម្ព័ន្ធ ខ.២៖ ទិដ្ឋភាពរួមនៃគម្រោងសំណងដែលបានកែសម្រួលរួចហើយ។ ឧបសម្ព័ន្ធ ខ.៤៖ ថវិកាគម្រោង ដែលបានកែសម្រួល។

[12] *សូមមើល* ឧបសម្ព័ន្ធ ខ.៥៖ ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ, កិច្ចព្រមព្រៀងនៃការផ្តល់ជំនួយគាំទ្ររបស់អង្គការ UNOPS (រួមបញ្ចូលព័ត៌មានលម្អិតអំពីគម្រោង និងថវិកាគម្រោង)។ ឧបសម្ព័ន្ធ ខ.៦៖ ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ , លិខិតពី Heinrich Böll Stiftung Cambodia។

ទាមទារសំណងចុងក្រោយ រួមទាំងការអភិវឌ្ឍខ្លឹមសារថ្មីសំខាន់ៗរបស់គម្រោង។ ឧទាហរណ៍ ដើម្បីបន្តខិតខំគាំទ្រគម្រោងសំណងដែលបានស្នើឡើងនៅក្នុងសំណុំរឿង ០០២/០២ សហភាពអឺរ៉ុប តាមរយៈអង្គការ UNOPS បានផ្តល់មូលនិធិបន្ថែមដើម្បីពង្រីកជំនួយលើគម្រោងដែលមានស្រាប់របស់ពួកគេ[13]។ ការពង្រីកគម្រោងនីមួយៗនឹងពាក់ព័ន្ធទៅនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងនាមជាសិទ្ធិវ័ន្ត។

១២. ជាពិសេស សហមេធាវីនាំមុខស្នើសុំឱ្យមានការបញ្ជាក់បំភ្លឺថា តើអង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាការបន្តសកម្មភាពបែបនេះថាជាការពង្រីកគម្រោងសំណងដែលបានស្នើឡើង អនុលោមតាមវិធាន ២៣*ស្ទួនបួន* (៣)(ខ) នៃវិធានផ្ទៃក្នុង[14] ឬ ថាតើសកម្មភាពទាំងនេះត្រូវបានចាត់ទុកថាជាគម្រោងរបស់អង្គការមិនមែនរដ្ឋាភិបាលដោយឡែកពីក្របខណ្ឌសំណងសម្រាប់ អ.វ.ត.ក [15]។ ផលវិបាកមួយក្នុងចំណោមផលវិបាកនានានៃការកំណត់លក្ខណៈរបស់វាគឺថា គម្រោងសំណងទាំងនេះអនុលោមតាមវិធាន ២៣*ស្ទួនបួន* (៣)(ខ) នៅពេលអានរួមជាមួយនឹងវិធាន ១២*ស្ទួន* (៣) នៃវិធានផ្ទៃក្នុងចែងព្យាករណ៍ទុកការចូលរួមរបស់សហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះនៅក្នុងការរៀបចំ និងការអនុវត្តគម្រោងបែបនេះ[16]។ ហេតុដូច្នេះ សហមេធាវីនាំមុខស្នើសុំគោលការណ៍ណែនាំអំពីកាតព្វកិច្ចរបស់ខ្លួនពាក់ព័ន្ធនឹងគម្រោងដូចបានរៀបរាប់ខាងក្រោម។

១៣. គេក៏ឃើញមានផលវិបាកសម្រាប់ដៃគូគម្រោងផងដែរ។ លក្ខខណ្ឌនៃលិខិតសហការដែលចុះហត្ថលេខាដោយដៃគូគម្រោងសំណងជម្រុញឱ្យដៃគូប្តេជ្ញាសហការ បន្តទំនាក់ទំនងប្រកបដោយប្រសិទ្ធ

---

[13] *សូមមើល* ឧបសម្ព័ន្ធ គ.១៖ លិខិតរបស់ UNOPS ស្តីពីចេតនា, សេចក្តីសង្ខេបនៃគម្រោងសំណង។

[14] សហមេធាវីនាំមុខសូមរំលឹកឡើងវិញនូវការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើគម្រោងទី ៥ និងគម្រោងទី ៦ នៅក្នុងសំណុំរឿង ០០២/០១ ក៏ប៉ុន្តែ ដោយសារការបង្កើតគម្រោង និងការសន្យាផ្តល់មូលនិធិដែលបានលើកឡើងនេះកើតឡើងនៅក្រោយពេលដាក់បណ្តឹងទាមទារសំណងចុងក្រោយនៅក្នុងសំណុំរឿង ០០២/០២ ស្ថានភាពមានលក្ខណៈខុសគ្នា។ *សូមមើល* សាលក្រមសំណុំរឿង ០០២/០១ ឯកសារ E313 កថាខណ្ឌ ១១៣១ កថាខណ្ឌ ១១៣២ កថាខណ្ឌ ១១៥៤ និងកថាខណ្ឌ ១១៥៥។

[15] វាក៏អាចត្រូវបានចាត់ទុកថាជាវិធានការក្រៅផ្លូវតុលាការផងដែរអនុលោមតាមវិធាន ១២ ស្ទួន (៤) ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយឡែករបស់អង្គភាពគាំពារជនរងគ្រោះ។

[16] ឧទាហរណ៍ សហមេធាវីនាំមុខធ្លាប់បានចូលរួមកាលពីលើកមុនពាក់ព័ន្ធនឹងការបង្កើតខ្លឹមសារគម្រោងដើម្បីឱ្យគម្រោង “បង្កើតឡើងដោយមានការពិចារណាលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានសច្ចធារណ៍និរទោស។ បញ្ហានេះគឺលេចចេញពីបទពិសោធន៍ដែល ដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង ហើយវាស្របតាមឧក្រិដ្ឋកម្មដែលជនជាប់ចោទកំពុងត្រូវបានជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២”។ *សូមមើល* សេចក្តីសន្និដ្ឋានរបស់សហមេធាវីនាំមុខអំពីគម្រោងសំណងអាទិភាព ឯកសារ E352/2/1 ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦ កថាខណ្ឌ ៥។

ភាព និងចែករំលែកព័ត៌មាន និងជាពិសេសសហការជាមួយនឹងសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះនៅក្នុងការរៀបចំ ការអភិវឌ្ឍ និងការអនុវត្តគម្រោងសំណងដែលបានស្នើឡើង [17] ។ លិខិតសហការក៏តម្រូវឱ្យដៃគូកំណត់សកម្មភាពគម្រោងថាជាផ្នែកមួយនៃគម្រោងសំណងដែលបានស្នើឡើងសម្រាប់ អ.វ.ត.ក ផងដែរ[18]។

១៤. ការពង្រីកសកម្មភាពបែបនេះនឹងប៉ះពាល់ដល់លទ្ធភាពរបស់អង្គជំនុំជម្រះក្នុងការទទួលស្គាល់ថាគម្រោងជាក់លាក់មួយផ្តល់សំណងសមស្រប តាមការទាមទាររបស់ សហមេធាវីនាំមុខ ដោយសារនៅពេលនេះដើមបណ្តឹងរដ្ឋប្បវេណីកាន់តែច្រើនអាចមានលទ្ធភាពទទួលប្រយោជន៍ពីគម្រោងសំណងដែលបានស្នើឡើងទាំងនេះ។ សហមេធាវីនាំមុខនៅតែរង់ចាំជួយជ្រោមជ្រែងដល់អង្គជំនុំជម្រះជានិច្ចប្រសិនបើមានការតម្រូវឱ្យដាក់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងសកម្មភាពបន្ថែម ក្របខណ្ឌពេលវេលា ការផ្តល់មូលនិធិ និងខ្លឹមសារសំខាន់ថ្មីៗ។

១៥. សហមេធាវីនាំមុខបានទទួលដំណឹងពីដៃគូគម្រោង និងអង្គភាពគាំពារជនរងគ្រោះអំពីការចាប់អារម្មណ៍របស់ម្ចាស់ជំនួយក្នុងការពង្រីកសកម្មភាពគម្រោងទាំង ៦ ដែលបានទទួលមូលនិធិពេញលេញ៖ “គម្រោង កម្មវិធីអេឡិចត្រូនិកសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម (គម្រោងទី ១) គម្រោងការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់លោកគ្រូ

[17] អត្ថបទទូទៅសម្រាប់រដ្ឋហត្ថលេខីលើកឡើងថា “រដ្ឋហត្ថលេខីទាំងអស់ទទួលស្គាល់ព្យសនកម្មដែល ដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង និងព្យាយាមលើកកម្ពស់គម្រោងសំណងដែលឆ្លើយតបចំពោះព្យសនកម្មរបស់ពួកគាត់។ រដ្ឋហត្ថលេខីទាំងអស់ចំពោះលិខិតសហការនឹងព្យាយាមសហការ បន្តធ្វើការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព និងចែករំលែកព័ត៌មានដើម្បីជាប្រយោជន៍ដល់ការសម្រេចបានគោលបំណងរួមក្នុងការទទួលបានសំណងតាមផ្លូវតុលាការប្រកបដោយអត្ថន័យ និងប្រសិទ្ធភាពសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី”។ ដៃគូគម្រោងយល់ស្រប “សហការជាមួយនឹងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអង្គភាពគាំពារជនរងគ្រោះនៅក្នុងការរៀបចំ ការបង្កើត និងការអនុវត្តគម្រោងសំណងនេះ។ ដៃគូគម្រោងក៏អាចចូលរួមនៅក្នុងការខិតខំរៃអង្គាសថវិកាដោយផ្ទាល់ជាមួយនឹងម្ចាស់ជំនួយសក្តានុពល ហើយនឹងជូនដំណឹងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអង្គភាពគាំពារជនរងគ្រោះប្រសិនបើពួកគេធានាបានការផ្តល់មូលនិធិលើគម្រោង។ ដៃគូគម្រោងអាចទទួលមូលនិធិគម្រោងដោយផ្ទាល់ និងអនុវត្តគម្រោងទៅតាមសំណើសុំដែលបានដាក់ជូនសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអង្គភាពគាំពារជនរងគ្រោះ។ ដៃគូគម្រោងត្រូវចាត់ទុកគម្រោងថាជាគម្រោងសំណងនៅក្នុងសំណុំរឿង ០០២/០២ អាស្រ័យលើស្ថានភាពបច្ចុប្បន្ននៃកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក នៅក្នុងបទបង្ហាញជាសាធារណៈទាំងអស់របស់ខ្លួន និងលិខិតឆ្លើយឆ្លងជាលាយលក្ខណ៍អក្សរត្រូវរួមបញ្ចូលភាសាដូចខាងក្រោម៖ “នេះជាគម្រោងសំណងតាមផ្លូវតុលាការដែលបានស្នើឡើងរបស់ អ.វ.ត.ក ដែលត្រូវបានបង្កើតឡើងសម្រាប់ផលប្រយោជន៍នៃដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២/០២””។

[18] *ដូចខាងលើ*។

អ្នកគ្រូ និងសាស្ត្រាចារ្យមហាវិទ្យាល័យ (គម្រោងទី ២) គម្រោងអណ្ដើក៖ គម្រោងអន្តរព័ត៌មានប្រកបដោយភាពច្នៃប្រឌិតដើម្បីលើកកម្ពស់ការយល់ដឹងអំពីប្រវត្តិសាស្ត្រ និងភាពក្លាហានរបស់ពលរដ្ឋនៅកម្ពុជា (គម្រោងទី ៣) គម្រោងផ្កាស្លាក្រោមអង្គារ (គម្រោងទី ៥) សំឡេងពីជនជាតិភាគតិច៖ ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការប្រព្រឹត្តមកលើជនជាតិភាគតិចវៀតណាម និងចាម ដែលបានរស់នៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងរបបខ្មែរក្រហម (គម្រោងទី ៦) និងគម្រោងផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់ (គម្រោងទី ៩)" ។ គម្រោងនីមួយៗក្នុងចំណោមគម្រោងទាំងនេះនឹងបន្តឱ្យដើមបណ្ដឹងរដ្ឋប្បវេណីបានបន្តចូលរួមសកម្មភាព និងអាចបានដល់ដើមបណ្ដឹងរដ្ឋប្បវេណីកាន់តែច្រើនតាមរយៈលទ្ធផលនៃការពង្រីកសកម្មភាពទាំងនេះ។

១៦. ទាក់ទងនឹង "គម្រោងកម្មវិធីអេឡិចត្រូនិកសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម" (គម្រោងទី ១) សហមេធាវីនាំមុខបានទទួលដំណឹងថា ការផ្ដល់មូលនិធិបន្ថែមនឹងផ្ដល់ជូនដោយសហភាពអឺរ៉ុបតាមរយៈអង្គការ UNOPS [19] សម្រាប់មជ្ឈមណ្ឌលបូផាណា ដើម្បីបង្កើតជំពូកខ្លឹមសារថ្មីអំពីប្រធានបទបន្ថែម [20] ។ ការផ្ដល់មូលនិធិបន្ថែមនឹងត្រូវបានប្រើប្រាស់ដើម្បីបង្កើតលទ្ធភាពប្រើប្រាស់កម្មវិធីនេះដោយសារគ្រូបង្រៀនចំនួន ៣០០ នាក់ មកពីវិទ្យាល័យ និងសាកលវិទ្យាល័យចំនួន ១៥០ នឹងត្រូវបានបណ្ដុះបណ្ដាលនៅក្នុងតំបន់ចំនួន១៥ [21] ។ ចំណុចចុងក្រោយ ផ្នែកថ្មីមួយនៃកម្មវិធីនេះ "សកម្មភាពចងចាំ" នឹងថតវីដេអូកិច្ចសន្ទនាអន្តរជំនាន់ចំនួន ៦០ រវាងអ្នករស់រានពីរបបខ្មែរក្រហម និងកូនៗរបស់ពួកគេ[22]។

១៧. សហភាពអឺរ៉ុបតាមរយៈអង្គការ UNOPS ក៏បង្ហាញបំណងចង់ផ្ដល់មូលនិធិបន្ថែមជូនមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីពង្រីកសកម្មភាព "គម្រោងការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈការបណ្ដុះបណ្ដាល និងសិក្ខាសាលាសម្រាប់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យមហាវិទ្យាល័យ (គម្រោងទី ២)"[23]។ លក្ខណៈ និងខ្លឹមសារនៃសកម្មភាពបន្តនេះកំពុងត្រូវបានពិនិត្យសម្រេចចុងក្រោយនៅឡើយ។

---

[19] *សូមមើល* ឧបសម្ព័ន្ធ គ.១៖ លិខិតរបស់ UNOPS ស្ដីពីចេតនា, សេចក្ដីសង្ខេបនៃគម្រោងសំណង។

[20] *សូមមើល* ឧបសម្ព័ន្ធ គ.២៖ លិខិតពីមជ្ឈមណ្ឌលបូផាណាកងសំណើសុំពង្រីកបន្ថែម។ បូផាណា បានចង្អុលបញ្ជាក់ថា ពួកគេក៏អាចទទួលថវិកាបន្ថែមពីមូលនិធិរ៉េ។ ចំពោះការអភិវឌ្ឍជំពូកមុនៗ សមាជិកផ្នែកបានចូលរួមកិច្ចប្រជុំគណកម្មាធិការវិទ្យាសាស្ត្រទទួលខុសត្រូវលើការអភិវឌ្ឍខ្លឹមសារនៃកម្មវិធី។

[21] *សូមមើល* ឧបសម្ព័ន្ធ គ.២៖ លិខិតពីមជ្ឈមណ្ឌលបូផាណា និងសំណើសុំពង្រីកបន្ថែម។

[22] *សូមមើល* ឧបសម្ព័ន្ធ គ.២៖ លិខិតពីមជ្ឈមណ្ឌលបូផាណា និងសំណើសុំពង្រីកបន្ថែម។

[23] *សូមមើល* ឧបសម្ព័ន្ធ គ.១៖ លិខិតរបស់ UNOPS ស្ដីពីចេតនា, សេចក្ដីសង្ខេបនៃគម្រោងសំណង។

១៨. សមាគមវប្បធម៌កម្ពុជា-អាល្លឺម៉ង់ រំពឹងថានឹងទទួលបានមូលនិធិបន្ថែមពីសហភាពអឺរ៉ុបតាមរយៈអង្គការ UNOPS ដើម្បីពង្រីកសកម្មភាពពាក់ព័ន្ធនឹង "គម្រោងអណ្ដើក៖ គម្រោងអន្តរព័ត៌មានប្រកបដោយភាពច្នៃប្រឌិតដើម្បីលើកកម្ពស់ការយល់ដឹងអំពីប្រវត្តិសាស្ត្រ និងភាពក្លាហានរបស់ពលរដ្ឋនៅកម្ពុជា (គម្រោងទី ៣)"[24] ។ មូលនិធិបន្ថែមនឹងអនុញ្ញាតឲ្យគម្រោងនេះចុះតាមខេត្តម្ដងទៀតដើម្បីធ្វើការសម្ដែងសិល្បៈបន្ថែម និងរៀបចំកិច្ចសន្ទនាអន្តរជំនាន់រវាងដើមបណ្ដឹងរដ្ឋប្បវេណី និងសិស្សនិស្សិត និងដើម្បីធ្វើការសិក្សាអង្កេតធ្វើតេស្តចំណេះដឹងសិស្សនិស្សិតអំពីរបបកម្ពុជាប្រជាធិបតេយ្យដោយសួរសំណួរដែលបានឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។ លើសពីនេះទៀត មូលនិធិបន្ថែមរំពឹងថានឹងយកទៅប្រើប្រាស់ដើម្បីរៀបចំព្រឹត្តការណ៍ដែលមានការចូលរួមពីដើមបណ្ដឹងរដ្ឋប្បវេណី និងយុវជននៅទួលស្លែង[25]។

១៩. អង្គការក្ដីករុណរំពឹងថានឹងទទួលបានមូលនិធិដើម្បីពង្រីកការតាំងពិពណ៌ កិច្ចសន្ទនាជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណី និងកម្រងប្រវត្តិសាស្ត្រដោយផ្ទាល់មាត់ដើម្បីជាផ្នែកមួយនៃ "គម្រោងផ្កាស្លាក្រោមអង្គការ" (គម្រោងទី ៥)[26]។ មូលនិធិនេះនឹងអនុញ្ញាតឲ្យបន្តសកម្មភាពគម្រោងសម្រាប់ឆ្នាំ ២០១៧ រហូតដល់ ឆ្នាំ ២០១៨ ដើម្បីបានទៅដល់សិទ្ធិវ័ន្តនៅតាមបណ្ដាខេត្ត។ លើសពីនេះហើយដោយសារវាពាក់ព័ន្ធនឹងសកម្មភាពនានា អង្គការក្ដីករុណានឹងមានលទ្ធភាពរៀបចំការតាំងពិពណ៌ចល័តចំនួនបី និងកិច្ចសន្ទនាអន្តរជំនាន់រវាងដើមបណ្ដឹងរដ្ឋប្បវេណី និងសហគមន៍នៅខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិន។ កម្រងប្រវត្តិសាស្ត្រដោយផ្ទាល់មាត់ចំនួន ១២ នឹងត្រូវបានចងក្រងពីកូនៗរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នករស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងខេត្តកំពង់ស្ពឺ ខេត្តត្បូងឃ្មុំ និងខេត្តស្វាយរៀង[27]។

២០. ពាក់ព័ន្ធនឹង "សំឡេងពីជនជាតិភាគតិច៖ ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការប្រព្រឹត្តមកលើជនជាតិភាគតិចវៀតណាម និងចាម ដែលបានរស់នៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងរបបខ្មែរក្រហម (គម្រោងទី ៦) អង្គការក្ដីករុណាបានទទួលមូលនិធិបន្ថែមពីក្រសួងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់ តាមរយៈសេវាសន្តិភាពសម្រាប់ពលរដ្ឋនៃ Deutsche Gesellschaft Für Internationale Zusammenarbei (GIZ) GmbH ដើម្បីបន្តសកម្ម

---

[24] *សូមមើល* ឧបសម្ព័ន្ធ គ.១៖ លិខិតរបស់ UNOPS ស្ដីពីចេតនា, សេចក្ដីសង្ខេបនៃគម្រោងសំណង។

[25] *សូមមើល* ឧបសម្ព័ន្ធ គ.៥៖ លិខិតពីអង្គការក្ដីករុណាពាក់ព័ន្ធនឹងសម្ដែងពីគម្រោងជនជាតិភាគតិច។

[26] *សូមមើល* ឧបសម្ព័ន្ធ គ.៤៖ លិខិតពីអង្គការក្ដីករុណាពាក់ព័ន្ធនឹងសម្ដែងពីគម្រោងផ្កាស្លា។

[27] *សូមមើល* ឧបសម្ព័ន្ធ គ.៤៖ លិខិតពីអង្គការក្ដីករុណាពាក់ព័ន្ធនឹងគម្រោងផ្កាស្លា។

ភាពរបស់ខ្លួនសម្រាប់ឆ្នាំ២០១៨[28] ។ មូលនិធិនេះនឹងអាចបន្តគម្រោងដើម្បីធ្វើសកម្មភាពពាក់ព័ន្ធបន្ថែមទៀត។ ការតាំងពិពណ៌ចល័តចំនួនពីរនៅក្នុងខេត្តស្វាយរៀង និងខេត្តកណ្ដាលនឹងរៀបចំឡើង ហើយកិច្ចសន្ទនាអន្តរជំនាន់នឹងរៀបចំឡើងរវាងយុវជន និងដើមបណ្ដឹងរដ្ឋប្បវេណី[29]។

២១. ចំណុចចុងក្រោយ ស្ថានទូតស្វីសនៅក្នុងទីក្រុងបាងកកបានផ្ដល់មូលនិធិជូន "គម្រោងផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់" (គម្រោងទី ៩) សម្រាប់អង្គការយុវសន្តិភាព និងវិទ្យាស្ថានសន្តិភាពនៃកម្ពុជាដើម្បីបន្តសកម្មភាពគម្រោងសម្រាប់រយៈពេលបន្ថែមចំនួន ៦ ខែដើម្បីឱ្យបានទៅដល់សិទ្ធិវ័ន្តបន្ថែមទៀត និងដើម្បីធ្វើសកម្មភាពពាក់ព័ន្ធបន្ថែមទៀត[30]។ សកម្មភាពទាំងនេះ រួមមានការបោះពុម្ពសៀវភៅប្រវត្តិសាស្ត្រក្រាំងតាចាន់ និងកូនសៀវភៅតាំងពិពណ៌ និងការសង់ផ្លូវដើរនៅជុំវិញទីតាំងឧក្រិដ្ឋកម្ម ធ្វើការលើកកម្ពស់ការយល់ដឹងរបស់សាធារណជន និងព្រឹត្តិការណ៍តាំងពិពណ៌នៅក្នុងខេត្តតាកែវដែលដើមបណ្ដឹងរដ្ឋប្បវេណីនឹងត្រូវបានអញ្ជើញឱ្យចូលរួម និងចែករំលែកបទពិសោធន៍របស់ពួកគេ ផ្ដល់ការបណ្ដុះបណ្ដាលស្ដីពីប្រវត្តិសាស្ត្រក្រាំងតាចាន់ និងការរៀបចំការតាំងពិពណ៌ជាសាធារណៈនៅក្នុងរាជធានីភ្នំពេញ[31]។

២២. ដោយពិចារណាលើការបន្តសកម្មភាពដែលបានស្រាប់ និងការបញ្ចូលសកម្មភាពពាក់ព័ន្ធដ៏ជិតស្និទ្ធផ្សេងទៀតដែលបង្កើនផលប្រយោជន៍សម្រាប់បណ្ដឹងដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីដោះស្រាយចំពោះព្យសនកម្មដែលពួកគាត់បានទទួលរងដោយសារឧក្រិដ្ឋកម្មនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ សហមេធាវីនាំមុខទទូចសុំឱ្យអង្គជំនុំជម្រះសាលាដំបូងដាក់បញ្ចូលការពង្រីកគម្រោងទាំងនេះទៅក្នុងការវិភាគរបស់ខ្លួនអំពីភាពសមស្របនៃសំណងដែលត្រូវផ្ដល់ជូន។ សហមេធាវីនាំមុខនឹងដាក់ជូននូវព័ត៌មានថ្មីៗ និងជាក់លាក់ជាងមុនពាក់ព័ន្ធនឹងគម្រោងទាំងនេះ

---

[28] *សូមមើល* ឧបសម្ព័ន្ធ គ.៥៖ លិខិតពីអង្គការក្ដីករុណាពាក់ព័ន្ធនឹងសម្លេងពីគម្រោងជនជាតិភាគតិច។ *សូមមើល* ឧបសម្ព័ន្ធ គ.៦៖ លិខិតពីក្រសួងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់ តាមរយៈសេវាសន្តិភាពសម្រាប់ពលរដ្ឋនៃ Deutsche Gesellschaft Für Internationale Zusammenarbei (GIZ) GmbH ពាក់ព័ន្ធនឹង "សម្លេងពីជនជាតិភាគតិច៖ ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការប្រព្រឹត្តលើជនជាតិភាគតិចវៀតណាម និងជនជាតិចាមដែលរស់នៅក្នុងរបបខ្មែរក្រហម"។

[29] *សូមមើល* ឧបសម្ព័ន្ធ គ.៥៖ លិខិតពីអង្គការក្ដីករុណាពាក់ព័ន្ធនឹងសម្លេងពីគម្រោងជនជាតិភាគតិច។

[30] *សូមមើល* ឧបសម្ព័ន្ធ គ.៧៖ លិខិតពីយុវសន្តិភាពពាក់ព័ន្ធនឹងគំនូររំលឹកការចងចាំគម្រោងក្រាំងតាចាន់ និងការពិពណ៌នាអំពីសកម្មភាពបន្ថែម។ ឧបសម្ព័ន្ធ គ.៨៖ កិច្ចព្រមព្រៀងរវាងស្ថានទូតនៃប្រទេសស្វីសនៅក្នុងទីក្រុងបាងកក និងអង្គការយុវសន្តិភាពពាក់ព័ន្ធនឹងគម្រោងរំលឹកការចងចាំអំពីក្រាំងតាចាន់។

[31] *សូមមើល* ឧបសម្ព័ន្ធ គ.៧៖ លិខិតពីយុវសន្តិភាពពាក់ព័ន្ធនឹងគំនូររំលឹកការចងចាំគម្រោងក្រាំងតាចាន់ និងការពិពណ៌នាអំពីសកម្មភាពបន្ថែម។

ប្រសិនបើអង្គជំនុំជម្រះស្នើសុំ។

### III. សំណើសុំ

២៣. សហមេធាវីនាំមុខសូមបញ្ជាក់សាជាថ្មីអំពីសំណើសុំរបស់ខ្លួននៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោល និងបណ្តឹងទាមទារសំណងចុងក្រោយដែលក្នុងនោះខ្លួនស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងដោយសារការប្រព្រឹត្តឧក្រិដ្ឋកម្មដែលតុលាការរកឃើញថាជនជាប់ចោទមានពិរុទ្ធភាព[32]។

**អាស្រ័យហេតុនេះ** យោងតាមហេតុផលដូចបានលើកឡើងខាងលើ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមគោរពស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង៖

(១) **ទទួលស្គាល់**ថា គម្រោងទី ១៣ និងគម្រោងទី ១៥ ឆ្លើយតបទៅនឹងព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង ដោយសារការប្រព្រឹត្តឧក្រិដ្ឋកម្មដែលតុលាការរកឃើញថាជនជាប់ចោទមានពិរុទ្ធភាព។

(២) **អនុម័ត**លើគម្រោងទី ១៣ និងគម្រោងទី ១៥ ថាផ្តល់សំណងសមស្របតាមការទាមទាររបស់សហមេធាវីនាំមុខ។

(៣) **ចាត់ទុកថា**មានការដកចេញនូវគម្រោងទី ១៤ គម្រោងទី ១៦ គម្រោងទី ១៧ និងគម្រោងទី ១៨។

(៤) **ផ្តល់គោលការណ៍ណែនាំ** ពាក់ព័ន្ធនឹងការផ្តល់មូលនិធិបន្ថែម និងសកម្មភាពសម្រាប់គម្រោងទី ១ គម្រោងទី ២ គម្រោងទី ៣ គម្រោងទី ៥ គម្រោងទី ៦ និងគម្រោងទី ៩។

សូមលោកលោកស្រីចៅក្រមទទួលយកសេចក្តីសន្និដ្ឋាននេះដោយក្តីគោរព។

---

[32] សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២/០២ ឯកសារ E457/6/2 ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៧ ផ្នែកសេចក្តីសម្រេច។ បណ្តឹងទាមទារចុងក្រោយរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណងនៅក្នុងសំណុំរឿង ០០២/០២ ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ ឯកសារ D457/6/2/1 ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៧ កថាខណ្ឌ ៨០។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៧ | ពេជ អង្គ<br>សហមេធាវីនាំមុខជាតិ | រាជធានីភ្នំពេញ | *[ហត្ថលេខា]* |
| | Marie GUIRAUD<br>សហមេធាវីនាំមុខអន្តរជាតិ | រាជធានីភ្នំពេញ | *[ហត្ថលេខា]* |